# ការរួមចំណែករបស់យុវជន/យុវតី ក្នុងការកាត់បន្ថយការជួញដូរសាច់ឆ្កែក្នុងប្រទេសកម្ពុជា

០១

ការលើកកម្ពស់ និង ផ្សព្វផ្សាយការយល់ដឹងអំពីហានិភ័យនៃការបរិភោគ សាច់ឆ្កែនៅក្នុងគ្រួសារ និងសហគមន៍របស់ខ្លួន

"កុំមើលស្រាល ប្រជាពលរដ្ឋមួយក្រុមតូចដែលមានគំនិត និងការប្តេជ្ញាចិត្តថាមិនអាចផ្លាស់ប្តូរពិភពលោកបាន! តែតាមការពិត វាជាអ្វីមួយដែលធ្លាប់កើតមាន "

" Never doubt that a small group of thoughtful, committed, citizens can change the world. Indeed, it is the only thing that ever has."

**Margaret Mead**



Credit: Dog Meat Trade - Four Paws



> ប្រទេសកម្ពុជាត្រូវបានគេស្គាល់ថាជាប្រទេសដែលមានអត្រាជំងឺឆ្កែឆ្កួតច្រើនជាងគេ ដោយសារកង្វះរ៉ាក់សាំងការពារជំងឺឆ្កែឆ្កួត ហើយត្រូវបានគេរាយការណ៍ថា មានមនុស្សជាង ៨០០ នាក់បានស្លាប់ដោយសារជំងឺឆ្កែឆ្កួតជារៀងរាល់ឆ្នាំ។

Khut Sopheak chariya, ភ្នំពេញ ប៉ុស្តិ៍, អាជ្ញាធរព្រមានចាត់វិធានការច្បាប់លើការលក់ ទិញ និងសម្លាប់ឆ្កែដោយខុសច្បាប់, ចេញថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០២០




០២





# ការជួញដូរសាច់ឆ្កែក្នុងប្រទេសកម្ពុជា

## តើកម្ពុជាគួរតែមានច្បាប់ហាមឃាត់ការជួញដូរសាច់ឆ្កែដែរឬទេ?

Creator: JUNG YEON-JE | Credit: AFP - Getty Images

សត្វឆ្កែជាសត្វចិញ្ចឹមដែលតែងតែទទួលបានការស្រឡាញ់ពីម្ចាស់ដោយសារភាពឈ្លាសវៃរបស់វា។ ក្រៅពីការយាមផ្ទះ សត្វឆ្កែត្រូវបានគេទទួលស្គាល់ថាវាមានតួនាទីជាច្រើនទៀតដូចជា វាត្រូវបានគេប្រើប្រាស់សម្រាប់ការជួយបោសសម្អាតមីន ការពារសន្តិសុខរបស់ម្ចាស់ និងជាដៃគូកំដរមនុស្សដ៏ស្មោះត្រង់។ ទោះជាយ៉ាងនេះក៏ដោយ សត្វឆ្កែនៅតែត្រូវបានគេលួចយកទៅជួញដូរ និង សម្លាប់ជាអាហារដោយសារតែ វាមានតម្លៃថោកជាងសាច់ដទៃ និង ការយល់ខុសអំពីគុណប្រយោជន៍នៃការបរិភោគសាច់ឆ្កែរបស់ប្រជាជនខ្មែរមួយចំនួន។

“ តើអ្នកដឹងទេថា យ៉ាងហោចណាស់មានសត្វឆ្កែប្រមាណជា ៣ លានក្បាលនៅក្នុងប្រទេសកម្ពុជា និង ៣០ លានក្បាលនៅ ក្នុងតំបន់អាស៊ីអាគ្នេយ៍ ត្រូវបានគេលួចមកជួញដូរជាអាហារជារៀងរាល់ឆ្នាំ? ”

FOUR PAWS, ការជួញដូរសាច់ឆ្កែនិងឆ្មាក្នុងតំបន់អាស៊ីអាគ្នេយ៍ ការគំរាមកំហែងទៅកាន់សត្វនិងមនុស្ស, ចេញខែកុម្ភៈ ឆ្នាំ ២០២០

# តើមានមូលហេតុអ្វីខ្លះដែលធ្វើឲ្យការជួញដូរសាច់ឆ្កែគួរតែត្រូវបានហាមឃាត់ ?



Credit: Vegan Lide Magazine



## ១ ការជួញដូរ និង ការបរិភោគសាច់ឆ្កែមិនមែនជាផ្នែកមួយនៃសាសនា និង វប្បធម៌ខ្មែរទេ

នៅក្នុងព្រះពុទ្ធសាសនា ការទទួលទានសាច់ឆ្កែ ត្រូវបានចាត់ទុកថាជាអំពើដែលមិនគប្បី។ ម្យ៉ាងវិញទៀត ការទទួលទានសាច់ឆ្កែក៏មិនដែលជាចំណែកនៃប្រពៃណី ឬវប្បធម៌ខ្មែរឡើយ។

## ២ ឥរិយាបថសង្គមខ្មែរចំពោះការជួញដូរសាច់ឆ្កែ

យោងតាមការស្ទង់មតិដែលធ្វើឡើងដោយអង្គការ FOUR PAWS បានបញ្ជាក់ថា ប្រជាជនខ្មែរភាគច្រើនមិនគាំទ្រការជួញដូរសាច់ឆ្កែទេ។ លើសពីនេះទៅទៀតបើផ្អែកលើការស្ទង់មតិរបស់យើង ក្នុងចំណោម ១០៩នាក់ នៃអ្នកឆ្លើយតប យើងបានទទួលការឆ្លើយតបចំនួន ១០៥នាក់ ដែលចង្អុលបង្ហាញថាការជួញដូរ សាច់ឆ្កែជាទង្វើខុសសីលធម៌ ឃោរឃៅ និងមិនអាចទទួលយកបាន។

## ៣ ជំនឿនៃការបរិភោគសាច់ឆ្កែ និងបញ្ហាសុខភាពដែលអាចបណ្តាលមកពីការទទួលទានសាច់ឆ្កែ

ប្រជាជនខ្មែរមួយចំនួនជឿថា ការបរិភោគសាច់ឆ្កែអាចរក្សារាងកាយអោយ-មានភាពកក់ក្តៅ ព្យាបាលជំងឺ បង្កើនថាមពលបុរស ជាពិសេសវាល្អសម្រាប់ស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលទើបសម្រាលបុត្ររួច ព្រោះវាអាចព្យាបាលមុខរបួសបានលឿនជាងមុន។ មកដល់បច្ចុប្បន្ននេះ មិនទាន់មានការស្រាវជ្រាវបែបវិទ្យាសាស្ត្រណាដែលហ៊ានអះអាងថា ការបរិភោគសាច់ឆ្កែល្អសម្រាប់សុខភាពនោះទេ។ ផ្ទុយទៅវិញ វាត្រូវបានគេដឹងថា ការទទួលទានសាច់ឆ្កែអាចបណ្តាលឱ្យកើត ជំងឺឆ្កែឆ្កួត ជំងឺអាសន្នរោគ និងជំងឺផ្សេងៗទៀត។

## ៤ បទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធនានានៃការហាមប្រាមសាច់ឆ្កែនៅកម្ពុជា

កម្ពុជាពុំមានច្បាប់ពិសេសដើម្បីហាមប្រាមការជួញដូរ និងប្រើប្រាស់សាច់ឆ្កែឡើយទេ។ ប៉ុន្តែនៅថ្ងៃទី 6 ខែកក្កដា ឆ្នាំ 2020 មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប បានចេញសេចក្តីជូនដំណឹងស្តីពី ហាមឃាត់ធ្វើអាជីវកម្មទិញ លក់ ពិឃាតសត្វសុនខ(ឆ្កែ)។ ក្រៅពីសេចក្តីជូនដំណឹងខាងលើ ការពិឃាតសាច់ឆ្កែ ដើម្បីយកសាច់ អាចនឹងល្មើស ច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្ម និង អនុក្រឹត្យលេខ១០៨ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ។ ចំណែកឯការផ្តន្ទាទោសដល់អ្នកលួច និង លក់សាច់ឆ្កែដែលដឹងថាវាត្រូវបានគេលួចពីម្ចាស់ឆ្កែ គឺប្រទេសកម្ពុជាយើងមានបទប្បញ្ញត្តិមួយចំនួននៅក្រោមក្រមព្រហ្មទណ្ឌកម្ពុជា ដែលអាចយកប្រើដើម្បីផ្តន្ទាទោសបាន។



## ឯកសារយោង៖


- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ 2007
- ច្បាប់ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា, ព្រះរាជក្រម លេខ. នស/រកម/០៦០០/០០១, ចេញថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១២
- ច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ព្រះរាជក្រម លេខ. នស/រកម/០១១៦/០០៣, ចេញថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៦
- អនុក្រឹត្យស្តីពី ការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យ សត្វ សាច់ និងផលិតផលសត្វ, លេខ ១០៨ អនក្រ.បក, ចេញថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៧
- នាយកដ្ឋានកសិកម្មនៃសាលាខេត្តសៀមរាប, សេចក្តីជូនដំណឹងស្តីពីការហាមឃាតជួញដូរនិងសម្លាប់សត្វឆ្កែ លេខ. ២៩៣ ចេញថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០២០
- FOUR PAWS, ការជួញដូរសាច់ឆ្កែនិងឆ្មាក្នុងតំបន់អាស៊ីអាគ្នេយ៍ ការគំរាមកំហែងទៅកាន់សត្វនិងមនុស្ស, ចេញខែកុម្ភៈ ឆ្នាំ ២០២០
- FOUR PAWS, ហេតុផលទាំង ១០ នៃការជួញដូរសាច់ឆ្កែនិងឆ្មាងតំបន់អាស៊ីអាគ្នេយ៍ ចេញថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៩
- FOUR PAWS International, របាយការណ៍លើការបរិភោគសាច់ឆ្កែក្នុងកម្ពុជាបញ្ឈប់ការជួញដូរសាច់ឆ្កែនិងឆ្មា, ចេញថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០២០
- Animal Rescue Cambodia, សាច់ឆ្កែ – ការយល់ខុសនិងហានិភ័យសុខភាពនៃការអនុវត្តដ៏សាហាវនេះ ចេញថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០២០
- One Green Plant, Sara Farr, បញ្ហាចម្បងទាំង ៣ ស្តីពីសុខភាពចំពោះអ្នកបរិភោគសាច់ឆ្កែគួរដឹង
- Animal Rescue Cambodia, ជំនឿលើការបរិភោគសាច់ឆ្កែ និង ហានិភ័យលើសុខភាព នៃការសម្លាប់បែបឃោរឃៅ
- Khut Sopheak chariya, ភ្នំពេញ ប៉ុស្តិ៍, អាជ្ញាធរព្រមានចាត់វិធានការច្បាប់លើការលក់ ទិញ និងសម្លាប់ឆ្កែដោយខុសច្បាប់, ចេញថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០២០


### គាំទ្រដោយ៖

R.U.L.E ELBBL English Language Based Bachelor of Law Program

RAOUL WALLENBERG INSTITUTE OF HUMAN RIGHTS AND HUMANITARIAN LAW

### រៀបរៀងដោយក្រុមនិស្សិត៖


កញ្ញា អ៊ឹង ស៊ូហុង
កញ្ញា ស៊ឹង រីសា
កញ្ញា សុខ សុនិតា
កញ្ញា សុខ សំលក្ខិណា



Material presented as a partial requirement for the completion of Professional Legal Skills (PLS) course from ELBBL Program of Royal University of Law and Economics (RULE), it is intended only for education purpose - knowledge sharing.
ខិត្តប័ណ្ណដែលបានបង្ហាញនេះ ជាផ្នែកមួយដែលត្រូវបំពេញសម្រាប់ការបញ្ចប់វគ្គជំនាញវិជ្ជាជីវៈច្បាប់ (PLS) ពីកម្មវិធី ELBBL នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច (RULE)។
ខិត្តប័ណ្ណនេះនឹងត្រូវប្រើប្រាស់សម្រាប់តែគោលបំណងនៃការអប់រំ - ការចែករំលែកចំណេះដឹងតែប៉ុណ្ណោះ។




Credit: Why Dog Meat Trade Needs to End! - Vietnam Insider